**ទាំងនេះគឺជាពរជ័យដែលយើងបានទទួលតាមរយៈការរស់នៅ តាមព្យាការីដែលកំពុងនៅរស់ ៖**



*ព្យាការី យ៉ូសែប ស្ម៊ីធ ( ឆ្នាំ ១៨០៥–៤៤ ) បានបកប្រែព្រះគម្ពីរមរមន « ដោយអំណោយទាន និង ព្រះចេស្ដានៃព្រះ » ( សូមមើលបុព្វកថាព្រះគម្ពីរមរមន ) ។ ចាប់តាំងពីការបោះពុម្ពនៅក្នុងឆ្នាំ ១៨៣០ មកគម្ពីរនេះបានប្រទានពរដល់ជីវិតមនុស្សរាប់លាននាក់ ។*



*នៅឆ្នាំ ១៩៣៦ អំឡុងពេលមានវិបត្តិធ្ងន់ធ្ងរ ប្រធាន ហ៊ីប៊ើរ ចេ ក្រាន្ត ( ឆ្នាំ ១៨៥៦–១៩៤៥ ) បានប្រកាសអំពីកម្មវិធីសុខុមាលភាពរបស់សាសនាចក្រ ។ សព្វថ្ងៃកម្មវិធីនេះជួយមនុស្សគ្រប់ជំនឿទាំងអស់នៅជុំវិញពិភពលោក ។*



*នៅខែមេសា ឆ្នាំ ១៩៩៨ នៅពេលសាសនាចក្រមានព្រះវិហារបរិសុទ្ធចំនួន៥១ កំពុងដំណើរការ នោះប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ ១៩១០–២០០៨ ) បានប្រកាសពីកម្មវិធីមួយដើម្បីសាងសង់ព្រះវិហារបរិសុទ្ធតូចៗជាច្រើន ។ ឥឡូវ ព្រះវិហារបរិសុទ្ធទាំងនេះបានប្រទានពរដល់សមាជិកសាសនាចក្រពាសពេញពិភពលោកកាន់តែច្រើនឡើងៗ ។*



*ក្នុងឆ្នាំ ១៩១៥ ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ( ឆ្នាំ ១៨៣៨–១៩១៨ ) និង ទីប្រឹក្សារបស់លោកបានអញ្ជើញសមាជិកទាំងអស់ឲ្យចាប់ផ្ដើមធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។ ក្រុមគ្រួសារជាច្រើននៅតែទទួលពរជ័យដ៏មហិមាជាលទ្ធផលដែលបានសន្យា ។*



*នៅក្នុងឆ្នាំ២០១២ ប្រធាន ថូម៉ាស អេស ម៉នសុន បានប្រកាសពីការបន្ថយអាយុឲ្យបម្រើជាអ្នកផ្សព្វផ្សាយសាសនា បុរសមកត្រឹមអាយុ ១៨ ឆ្នាំ ហើយស្ត្រីអាយុ ១៩ វិញ ។ គ្រួសារ និង អ្នកផ្សព្វផ្សាយសាសនារាប់ពាន់នាក់បានទទួលពរ តាមរយៈលទ្ធផលនៃការបង្កើនកម្លាំងយ៉ាងច្រើននៃអ្នកផ្សព្វផ្សាយសាសនា ។*

រូបគំនូរដោយ ជេ បេិត ប៊ីបសុន